វាយសារឡើងវិញជាភាសារខ្មែរប្រែពីឯកសារផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ : ១០៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និងមត្តេយ្យសិក្សា ជាពីរនាយកដ្ឋាន គឺនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច ចំណុះអគ្គនាយកដ្ឋានអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២.-**

នាយកដ្ឋាននីមួយៗ មានមុខងារ និងភារកិច្ច :

**ក.** នាយកដ្ឋានបឋមសិក្សា

- អភិវឌ្ឍន៍អប់រំបឋមសិក្សា សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា
- លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំបឋមសិក្សារយៈពេលវែង មធ្យម ខ្លី
- កែលំអការអប់រំបឋមសិក្សា ដើម្បីធានាការចូលរៀនប្រកបដោយសមធម៌ និងគុណភាពអប់រំប្រកប ដោយប្រសិទ្ធភាព
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ការអប់រំ បឋមសិក្សា
- គ្រប់គ្រងនិងត្រួតពិនិត្យដំណើរការសិក្សា នៅគ្រប់គ្រឹះស្ថានបឋមសិក្សារដ្ឋ និងឯកជនលើការងាររដ្ឋបាល និងបច្ចេកទេស
- តាមដានត្រួតពិនិត្យ និងកែលំអការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ
- សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាបឋមសិក្សារដ្ឋ និងឯកជន និងសំណើបង្រៀនថ្នាក់ពីរពេល ថ្នាក់គួប

**ខ.** នាយកដ្ឋានអប់**រំកុមារតូច**

- អភិវឌ្ឍន៍អប់រំកុមារតូច (០-៦ ឆ្នាំ) សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា
- លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំកុមារតូច រយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យអប់រំកុមារតូច
- គ្រប់គ្រង និងត្រួតពិនិត្យថ្នាក់ និងសាលាមត្តេយ្យសិក្សាទាំងរដ្ឋ និងឯកជន លើការងាររដ្ឋបាលនិងបច្ចេកទេស
- ជម្រុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និងជម្រុញគោលការណ៍អប់រំសហគមន៍ (ម្តាយ) ដើម្បីធានាថែទាំកុមារ ទាំងសុខភាព ទាំងបញ្ញា ដោយសហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការ ជាតិ អន្តរជាតិ និងសហគមន៍
- តាមដានត្រួតពិនិត្យ និងកែលំអ ការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ
- សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាមត្តេយ្យសិក្សារដ្ឋ និងឯកជន និងសំណើផ្សេងៗ ពាក់ព័ន្ធមត្តេយ្យសិក្សា និងទារកដ្ឋាន

**មាត្រា ៣.-**

នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច ត្រូវដឹកនាំដោយប្រធាន មួយរូប និង អនុប្រធាន ជាជំនួយការ មួយរូប ឬច្រើនរូបតាមការចាំបាច់។

**មាត្រា ៤.-**

ភារកិច្ចជាក់ស្តែង និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តន៍ អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>** :

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ " ដើម្បីអនុវត្តន៍ "
- ឯកសារ - កាលប្បវត្តិ